**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# រូបសញ្ញានិងត្រារបស់ស្ថាប័នប្រឆាំងអំពើពុករលួយ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០១/០៣០ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០១ ស្តីពីសញ្ញារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១០

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតរូបសញ្ញានិងត្រារបស់ស្ថាប័នប្រឆាំងអំពើពុករលួយ សម្រាប់ប្រើប្រាស់ក្នុងដំណើរការការងាររបស់ខ្លួន។

ស្ថាប័នប្រឆាំងអំពើពុករលួយសរសេរអក្សរកាត់ថា ស.ប.ព. ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយសរសេរអក្សរកាត់ថា ក.ជ.ប.ព. និងអង្គភាពប្រឆាំងអំពើពុករលួយសរសេរអក្សរកាត់ថា អ.ប.ព.។

**មាត្រា ២.-**

ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយប្រើប្រាស់រួមគ្នារូបសញ្ញារបស់ស្ថាប័នប្រឆាំងអំពើពុករលួយ។

រូបសញ្ញារបស់ស្ថាប័នប្រឆាំងអំពើពុករលួយមានរូបភាព និងខ្នាតដូចតទៅ៖

-ខ្សែរង្វង់រាងពងក្រពើមានផ្ទៃអមសងខាងពណ៌ខៀវនិងផ្ទៃខាងក្នុងពណ៌ក្រហម មានចារឹកអក្សរខ្មែរពណ៌សថា " ព្រះរាជាណាចក្រកម្ពុជា " នៅផ្នែកខាងលើ និងចារឹកអក្សរឡាតាំងជាភាសាអង់គ្លេសថា "KINGDOM OF CAMBODIA " នៅផ្នែកខាងក្រោម តំណាងឱ្យប្រជាជាតិខ្មែរ

-នៅខាងក្នុងរង្វង់រាងពងក្រពើ មានផ្ទៃពណ៌ស រំលេចរូបសញ្ញារាជរដ្ឋាភិបាលពណ៌មាស តំណាង ឱ្យស្ថាប័ននីតិប្រតិបត្តិ

-នៅខាងក្នុងរង្វង់រាងពងក្រពើ ផ្នែកខាងក្រោម មានចារឹកអក្សរខ្មែរពណ៌ខៀវថា ស្ថាប័នប្រឆាំងអំពើពុករលួយ និងអក្សរកាត់ថា "ស.ប.ព." នៅខាងក្រោម ដែលជាយន្តការជាតិក្នុងការប្រឆាំងអំពើ-ពុករលួយ

-ផ្ទៃពណ៌ស និងអក្សរពណ៌ស តំណាងឱ្យសុចរិត និងភាពស្អាតស្អំនៃសង្គមជាតិ

-ខ្សែបូពណ៌មាសទ្រពីក្រោមមានចារឹកអក្សរឡាតាំងជាភាសាអង់គ្លេសពណ៌សថា "ANTI-CORRUPTION INSTITUTION" និងអក្សរកាត់ថា "ACI" តំណាងឱ្យការចូលរួមគាំទ្រពីមហាជន និងកិច្ចសហប្រតិបត្តិការពីសហគមន៍តំបន់ និងអន្តរជាតិក្នុងការប្រឆាំងអំពើពុករលួយ

-រូបសញ្ញារបស់ស្ថាប័នប្រឆាំងអំពើពុករលួយមានទទឹង ៣ ភាគ ៤ នៃបណ្តោយ ។

រូបសញ្ញាដែលមានខ្លឹមសារដូចបានចែងខាងលើ ជាឧបសម្ព័ន្ធ១នៃអនុក្រឹត្យនេះ ។

**មាត្រា ៣.-**

រូបសញ្ញារបស់ស្ថាប័នប្រឆាំងអំពើពុករលួយត្រូវបានប្រើប្រាស់ ដូចខាងក្រោម៖

-ដាក់នៅកន្លែងធ្វើការរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ

-ដាក់នៅលើក្បាលលិខិតផ្លូវការរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយ

-បំពាក់លើឯកសណ្ឋានរបស់កម្លាំងសន្តិសុខ នៃអង្គភាពប្រឆាំងអំពើពុករលួយ

-ប្រើប្រាស់សម្រាប់ស្ថាប័នប្រឆាំងអំពើពុករលួយ ក្នុងករណីផ្សេងៗទៀត។

**មាត្រា ៤.-**

ស្ថាប័នប្រឆាំងអំពើពុករលួយមានត្រាមូលពីរគឺត្រាប្រើប្រាស់សម្រាប់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងត្រាប្រើប្រាស់សម្រាប់អង្គភាពប្រឆាំងអំពើពុករលួយ។

ត្រារបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ មានរណ្តៅពីរជាន់ រំលេចរូបប្រាសាទអង្គរវត្តកំពូលបីនៅចំកណ្តាល។ នៅខាងក្រោមរូបប្រាសាទអង្គរវត្តកំពូលបីមានឆ្លាក់អក្សរ "ស្ថាប័នប្រឆាំងអំពើពុករលួយ" ។ ផ្នែកខាងលើមានឆ្លាក់អក្សរ "ព្រះរាជាណាចក្រកម្ពុជា" ស្របតាមរណ្តៅ ផ្នែកខាងក្រោមមានឆ្លាក់អក្សរ "ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ" ស្របតាមរណ្តៅ និងនៅចន្លោះពាក្យទាំងពីរ មានរូបផ្កាចន្ទន៍នៅសងខាង។

ត្រារបស់អង្គភាពប្រឆាំងអំពើពុករលួយ មានរណ្តៅពីរជាន់ រំលេចរូបប្រាសាទអង្គរវត្តកំពូលបី នៅចំកណ្តាល។ នៅខាងក្រោមរូបប្រាសាទអង្គរវត្តកំពូលបីមានឆ្លាក់អក្សរ "ស្ថាប័នប្រឆាំងអំពើពុករលួយ" ។

ផ្នែកខាងលើមានឆ្លាក់អក្សរ "ព្រះរាជាណាចក្រកម្ពុជា" ស្របតាមវណ្ណ ផ្នែកខាងក្រោមមានឆ្លាក់អក្សរ "អង្គភាពប្រឆាំងអំពើពុករលួយ" ស្របតាមវណ្ណ និងនៅចន្លោះពាក្យទាំងពីរ មានរូបផ្កាចន្ទន៍នៅសងខាង ។

ត្រាដែលមានខ្លឹមសារដូចបានថែងខាងលើ ជាឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ ។

ក្រៅពីនេះប្រធានអង្គភាពប្រឆាំងអំពើពុករលួយអាចបង្កើតឲ្យមានត្រាប្រើប្រាស់តាមជំនាញ និងតាមចេនាសម្ព័ន្ធរបស់ខ្លួននៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋានតាមការចាំបាច់។

**មាត្រា ៥.-**

អនុក្រឹត្យលេខ២១ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៨ ស្តីពីរូបសញ្ញានៃអង្គភាពប្រឆាំងអំពើពុករលួយ និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១១*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ១ នៃអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ២០១១

ឧបសម្ព័ន្ធ២ នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ២០១១






